# និយ័តករគណនេយ្យនិងសវនកម្ម

## ព្រឹត្តិបត្រព័ត៌មានប្រចាំខែមេសា ឆ្នាំ២០២៥

លេខ:០០៤


សេចក្ដីសង្ខេបព័ត៌មាន និងព្រឹត្តិការណ៍សំខាន់ៗប្រចាំខែមេសា របស់និយ័តករគណនេយ្យ និងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ រួមមានដូចខាងក្រោម៖

## ពិធី "ប្រកាសដាក់ឱ្យប្រើប្រាស់មុខងាររបស់ FMIS និងអនុវត្តនីតិវិធីតាម FMIS ទាំងស្រុងជាផ្លូវការ "



១.កាលពីថ្ងៃព្រហស្បតិ៍ ១៣កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស២៥៦៨ ត្រូវនឹងថ្ងៃទី១០ ខែមេសាគ.ស.២០២៥ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយមន្ត្រីជំនាញបានចូលរួមពិធី"ប្រកាសដាក់ឱ្យប្រើប្រាស់មុខងាររបស់ FMIS និងអនុវត្តនីតិវិធីតាម FMIS ទាំងស្រុងជាផ្លូវការ" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម-អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និងមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងដៃគូអភិវឌ្ឍន៍។

## កិច្ចប្រជុំលើកទី១ របស់គណៈកម្មការបច្ចេកទេសស្តង់ដាគណនេយ្យសម្រាប់វិស័យសាធារណៈ



# ព័ត៌មានថ្មីៗ


ពិធីប្រកាស សូមអាននៅទំព័រ................................១
កិច្ចប្រជុំលើកទី១ សូមអាននៅទំព័រ...................... ២
ពិធីប្រកាសដាក់ សូមអាននៅទំព័រ ........................២
កិច្ចប្រជុំបច្ចេកទេស សូមអាននៅទំព័រ....................៣
ការធ្វើបទបង្ហាញ សូមអាននៅទំព័រ........................៣
កិច្ចប្រជុំ សូមអាននៅទំព័រ...................................៣
វគ្គបណ្តុះបណ្តាល សូមអាននៅទំព័រ.......................៤
សិក្ខាសាលាស្តីពី សូមអាននៅទំព័រ........................៤
សិក្ខាសាលាផ្សព្វផ្សាយស្តីពី សូមអាននៅទំព័រ..........៥
ការប្រឡងប្រជែងផ្ទៃក្នុង សូមអាននៅទំព័រ...............៥
ក្រុមការងាររៀបចំវេទិកាជាតិ សូមអាននៅទំព័រ.........៥
កិច្ចប្រជុំស្តីពី សូមអាននៅទំព័...............................៦
ជួបពិភាក្សា សូមអាននៅទំព័................................៦
វគ្គបណ្តុះបណ្តាលស្តីពី សូមអាននៅទំព័រ................៧
សិក្ខាសាលាផ្សព្វផ្សាយស្តីពី សូមអាននៅទំព័រ..........៧
វគ្គបណ្តុះបណ្តាលស្តីពី សូមអាននៅទំព័រ..................៨
កិច្ចប្រជុំពិភាក្សា សូមអាននៅទំព័រ.........................៨
កិច្ចប្រជុំស្តីពី សូមអាននៅទំព័រ..............................៩
កិច្ចប្រជុំពិគ្រោះយោបល់ សូមអាននៅទំព័រ..............៩



© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម


Facebook Website Telegram

២.កាលពីថ្ងៃពុធ ១២កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៩ ខែមេសា គ.ស.២០២៥ នៅបន្ទប់ប្រជុំធំ អគារ "គ" នៃទីស្ដីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **ឯកឧត្ដម ទី តាយី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការបច្ចេកទេសស្តង់ដាគណនេយ្យសម្រាប់វិស័យសាធារណៈ បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ ដឹកនាំកិច្ចប្រជុំលើកទី១ របស់គណៈកម្មការបច្ចេកទេសស្តង់ដាគណនេយ្យសម្រាប់វិស័យសាធារណៈ (គ.ស.ស.) ដោយមានការអញ្ជើញចូលរួមពី **ឯកឧត្តម អួន ប៊ុនហាក់** អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង **លោកជំទាវ រស់ ច័ន្ទស្រស់** អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំង ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា ដែលជាសមាជិក សមាជិកានៃគណៈកម្មការបច្ចេកទេសស្តង់ដាគណនេយ្យសម្រាប់វិស័យសាធារណៈ សរុបប្រមាណជិត ៣០នាក់ ដើម្បីពិនិត្យ និងពិភាក្សាលើរបៀបវារៈ ដូចខាងក្រោម៖១)ការណែនាំសមាជិកនៃគណៈកម្មការបច្ចេកទេសស្តង់ដាគណនេយ្យសម្រាប់វិស័យសាធារណៈ ២)ពិនិត្យនិងសម្រេចលើសេចក្ដីព្រាងស្តង់ដាគណនេយ្យសាធារណៈកម្ពុជាលេខ១ ស្តីពីការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុ, លេខ២ ស្ដីពីរបាយការណ៍លំហូរសាច់ប្រាក់ និងលេខ១២ ស្ដីពីសន្និធិ, និងសេចក្ដីព្រាងប្រកាស, ៣)ពិនិត្យ និងផ្ដល់យោបល់លើសេចក្ដីព្រាងស្តង់ដាគណនេយ្យសាធារណៈកម្ពុជា លេខ១៤ ស្ដីពីព្រឹត្តិការណ៍បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ និងលេខ២០ ស្ដីពីការលាតត្រដាងអំពីភាគីពាក់ព័ន្ធ និង៤)របៀបវារៈផ្សេងៗ។

## ពិធីប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនូវ "យុទ្ធសាស្ត្រស្ដីពីការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ឆ្នាំ ២០២៥ - ២០២៨"



៣.កាលពីថ្ងៃពុធ ១១រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៣ ខែមេសា គ.ស.២០២៥ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម បានចូលរួមពិធីប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនូវ "យុទ្ធសាស្ត្រស្ដីពីការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ចឆ្នាំ ២០២៥ - ២០២៨" ។ ពិធីខាងលើបានប្រព្រឹត្តិនៅសណ្ឋាគារ ហៃយ៉ាត រីជីនស៊ី ភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** តំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

## កិច្ចប្រជុំបច្ចេកទេសអន្តរភាពក្រោមឱវាទ អ.ស.ហ. តាមប្រព័ន្ធអនឡាញ



៤.កាលពីថ្ងៃអង្គារ ៤កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១ ខែមេសា គ.ស.២០២៥ **ឯកឧត្តម ម៉ី ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយមន្ត្រីជំនាញនៃ ន.គ.ស. បានចូលរួមកិច្ចប្រជុំបច្ចេកទេសអង្គភាពក្រោមឱវាទ អ.ស.ហ. តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សា អ.ស.ហ. ដើម្បីពិនិត្យ និងផ្តល់យោបល់ទៅលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្តជាកាតព្វកិច្ច។

## ការធ្វើបទបង្ហាញស្តីពីអត្ថប្រយោជន៍របស់ ប.ស.ស.




៥.កាលថ្ងៃអង្គារ ៤កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១ ខែមេសា គ.ស.២០២៥ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ី ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម បានសហការជាមួយបេឡាជាតិសន្តិសុខសង្គម រៀបចំការធ្វើបទបង្ហាញស្តីពីអត្ថប្រយោជន៍របស់ ប.ស.ស. និងការចុះកំណត់អត្តសញ្ញាណក្នុងការធ្វើបណ្ណ ប.ស.ស. ជូនដល់មន្ត្រីលក្ខន្តិកៈ មន្ត្រីជាប់កិច្ចសន្យារបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដែលបម្រើការងារនៅ ន.គ.ស. ទាំងអស់ នៅអគារ៣៤៥។

## កិច្ចប្រជុំជាមួយអ្នកជំនាញការរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)




៦.កាលពីថ្ងៃពុធ ៥កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២ ខែមេសា គ.ស.២០២៥ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ី ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម លោកស្រី នាន បូនី អគ្គនាយករង អមដោយថ្នាក់ដឹកនាំនៃ ន.គ.ស. បានចូលរួមកិច្ចប្រជុំជាមួយ លោក សុខ កែវស្មី អ្នកជំនាញការក្នុងស្រុក និង Dr. Satyaveer Signh អ្នកជំនាញការរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ទទួលបន្ទុករៀបចំក្របខណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃសមិទ្ធកម្មរបស់ អ.ស.ហ. នៅទីស្តី ក.ស.ហ.វ.។ កិច្ចប្រជុំនេះរៀបចំឡើងដើម្បីសិក្សានិងប្រមូលធាតុចូលក្នុងការរៀបចំឯកសារណែនាំស្តីពីការតាមដាននិងវាយតម្លៃសមិទ្ធកម្មរបស់ អ.ស.ហ. និងឯកសារស្តីពីការកំណត់ សូចនាករសមិទ្ធកម្មគន្លឹះ ដើម្បីវាស់វែងប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រនានារបស់ អ.ស.ហ.។



© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម

## វគ្គបណ្តុះបណ្តាលស្តីពី "ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាស ធុនតូចនិងមធ្យម"ជូនមន្ត្រីនៃអគ្គនាយកដ្ឋានពន្ធដារ



៧.កាលពីថ្ងៃចន្ទ ១០កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៧ ខែមេសា គ.ស.២០២៥ និយ័តករគណនេយ្យនិងសវនកម្ម សហការជាមួយអគ្គនាយកដ្ឋានពន្ធដារ និងក្រុមហ៊ុនឌីអេស្វស៊ី បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម"វគ្គទី១ ឆ្នាំ២០២៥ ជូនដល់មន្ត្រី នៃអគ្គនាយកដ្ឋានពន្ធដារ។ វគ្គបណ្តុះបណ្តាលនេះប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម ព្រមទាំងមានការអញ្ជើញចូលរួមពី **ឯកឧត្តម កែន សម្បត្តិ** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ និង **លោក សាយ សុខខេង** អគ្គនាយកក្រុមហ៊ុនឌីអេស្វស៊ី ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រី នៃនិយ័តករគណនេយ្យនិងសវនកម្មនិងមន្ត្រីនៃអគ្គនាយកដ្ឋានពន្ធដារចំនួន៥៥នាក់។

## សិក្ខាសាលាស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ របស់ អ.ស.ហ.



៨.កាលពីថ្ងៃអង្គារ ១១កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៨ ខែមេសា គ.ស.២០២៥ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម លោក ទឹម សត្យា អនុប្រធាននាយកដ្ឋានទទួលបន្ទុករួមនៃនាយកដ្ឋានកិច្ចការទូទៅនិងមន្ត្រីជំនាញ បានចូលរួមសិក្ខាសាលាស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ របស់ អ.ស.ហ. ដែលដឹកនាំដោយ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អ.ស.ហ.។

## សិក្ខាសាលាផ្សព្វផ្សាយស្តីពីការប្រកាសដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍវិស័យបរធនបាលកិច្ច ឆ្នាំ ២០២៥-២០៣៥



៩.កាលពីថ្ងៃពុធ ១២កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៩ ខែមេសា គ.ស.២០២៥ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម លោកស្រី នាន បូនី អគ្គនាយករង អមដោយថ្នាក់ដឹកនាំនិងមន្ត្រីជំនាញបានចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្តីពី"ការប្រកាសដាក់ឱ្យអនុវត្តយុទ្ធសាស្រ្តអភិវឌ្ឍវិស័យបរធនបាលកិច្ច ឆ្នាំ២០២៥-២០៣៥" នៅសណ្ឋាគារសុខាភ្នំពេញ។ សិក្ខាសាលាខាងលើប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម មី វ៉ាន់** រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។**

## ការប្រឡងប្រជែងផ្ទៃក្នុងផ្លាស់ប្តូរប្រភេទមន្ត្រីលក្ខន្តិកៈ សម្រាប់មន្ត្រីលក្ខន្តិកៈរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ



១០.កាលពីថ្ងៃចន្ទ ៩រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២១ ខែមេសា គ.ស.២០២៥ និយ័តករគណនេយ្យនិងសវនកម្ម បានរៀបចំការប្រឡងប្រជែងផ្ទៃក្នុងផ្លាស់ប្តូរប្រភេទមន្ត្រីលក្ខន្តិកៈ សម្រាប់មន្ត្រីលក្ខន្តិកៈរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បម្រើការងារនៅនិយ័តករគណនេយ្យនិងសវនកម្មនៅអគារ៣៤៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម និងជាប្រធានគណៈកម្មការរៀបចំការប្រឡង អមដោយលោកអគ្គនាយករង ដែលជាអនុប្រធានគណៈកម្មការ ព្រមជាមួយលោក លោកស្រី អនុប្រធាននាយកដ្ឋាន និងប្រធាន-អនុប្រធានការិយាល័យ ជាសមាជិក។

## កិច្ចប្រជុំវឌ្ឍនភាពរបស់ក្រុមការងាររៀបចំវេទិកាជាតិគណនេយ្យឆ្នាំ២០២៥




១១.កាលពីថ្ងៃអង្គារ ១០រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៣ ខែមេសា គ.ស.២០២៥ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម បានបន្តដឹកនាំកិច្ចប្រជុំពិភាក្សាលើការងាររៀបចំវេទិកាជាតិគណនេយ្យឆ្នាំ២០២៥ នៅបន្ទប់ប្រជុំធំនិយ័តករគណនេយ្យនិងសវនកម្ម ដោយមានការចូលរួមពីថ្នាក់ដឹកនាំ ន.គ.ស. ថ្នាក់ដឹកនាំវិទ្យាស្ថានគណនេយ្យករជំនាញ

និងសវនករកម្ពុជា លោកប្រធាន ACCA ប្រចាំកម្ពុជា ព្រមទាំងក្រុមការងាររៀបចំវេទិកាជាតិគណនេយ្យឆ្នាំ២០២៥ ដែលវេទិកានឹងប្រព្រឹត្តិទៅនាដើមខែកញ្ញា ឆ្នាំ២០២៥ ខាងមុខ។

## កិច្ចប្រជុំស្តីពីការចែករំលែកព័ត៌មានស្តីពី "ការចូលរួមវេទិកាប្រឹក្សាយោបល់ស្តង់ដាគណនេយ្យ ឆ្នាំ២០២៥ និងការធ្វើទស្សនកិច្ចសិក្សា"




១២.កាលពីថ្ងៃអង្គារ ១០រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២២ ខែមេសា គ.ស.២០២៥ និយ័តករគណនេយ្យនិងសវនកម្ម បានរៀបចំកិច្ចប្រជុំស្តីពីការចែករំលែកព័ត៌មានស្តីពី "ការចូលរួមវេទិកាប្រឹក្សាយោបល់ស្តង់ដាគណនេយ្យឆ្នាំ២០២៥ និងការធ្វើទស្សនកិច្ចសិក្សា" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម អមដោយលោក លោកស្រីអនុប្រធាននាយកដ្ឋាន និងមន្ត្រីនៃនិយ័តករគណនេយ្យនិងសវនកម្ម។ គោលបំណងនៃបទបង្ហាញនេះគឺដើម្បីចែករំលែកបទពិសោធន៍ព័ត៌មានដែលទទួលបានពីការចូលរួម វេទិកាកាលពីថ្ងៃទី២៤-២៦ ខែមីនា ឆ្នាំ២០២៥ នៅទីក្រុងឡុងដ៏ ចក្រភពអង់គ្លេស ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍន៍ស្ថាប័ន ន.គ.ស. ផងដែរ។

## ជួបពិភាក្សាជាមួយតំណាងសាកលវិទ្យាល័យ អន្តរជាតិផារ៉ាហ្គន




១៣.កាលពីថ្ងៃព្រហស្បតិ៍ ១២រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៤ ខែមេសា គ.ស.២០២៥ នៅនិយ័តករគណនេយ្យនិងសវនកម្ម ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម លោកស្រី នាន បូនី អគ្គនាយករង អមដោយលោក ណុប សម្បត្តិ អនុប្រធាននាយកដ្ឋានគ្រប់គ្រងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម, លោក សាយ សុខខេង ទីប្រឹក្សាបច្ចេកទេស និងមន្ត្រីជំនាញបានជួបពិភាក្សាជាមួយតំណាងសាកលវិទ្យាល័យអន្តរជាតិផារ៉ាហ្គន។ កិច្ចប្រជុំនេះក្នុងគោលបំណង គឺដើម្បីជួបពិភាក្សានិងស្នើសុំការសហការលើរបៀបវារៈដូចជា៖ទី១.ស្នើសុំពិភាក្សាស្តីពីការចុះអនុស្សារណៈយោគយល់គ្នារវាងនិយ័តករគណនេយ្យនិងសវនកម្ម និងសាកលវិទ្យាល័យ អន្តរជាតិផារ៉ាហ្គន ទី២.ការបើកបង្រៀនថ្នាក់ កម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា ទី៣.ការចូលរួមផ្សព្វផ្សាយលើកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា និងទី៤.ការពង្រីកសក្តានុពលកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា ជាមួយនិយ័តករគណនេយ្យនិងសវនកម្ម និងសាកលវិទ្យាល័យអន្តរជាតិផារ៉ាហ្គន។

## វគ្គបណ្តុះបណ្តាលស្តីពីមូលដ្ឋានគ្រឹះគណនេយ្យមុននឹងសិក្សាស្តង់ដាគណនេយ្យ



១៤.កាលពីថ្ងៃព្រហស្បតិ៍ ១២រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៤ ខែមេសា គ.ស.២០២៥ និយ័តករគណនេយ្យនិងសវនកម្ម បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីមូលដ្ឋានគ្រឹះគណនេយ្យមុននឹងសិក្សាស្តង់ដាគណនេយ្យ ក្រោមអធិបតីភាព លោកស្រី នាន បូនី អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម។ វគ្គបណ្តុះបណ្តាលនេះរៀបចំឡើងក្នុងគោលបំណងផ្តល់ការបណ្តុះបណ្តាលជាមូលដ្ឋានជូនដល់សិក្ខាកាម ដែលអាចយកចំណេះដឹងទាំងនេះយកទៅអនុវត្តក្នុងកិច្ចការប្រចាំថ្ងៃសម្រាប់អង្គភាព ដែលកំពុងបំពេញការងារជាពិសេសគឺអាចឈានបន្តទៅវគ្គស៊ីជម្រៅមួយទៀតដែលហៅថា វគ្គស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម (CIFRS for SMEs)។

## សិក្ខាសាលាផ្សព្វផ្សាយស្តីពី "កម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា"



១៥.កាលពីថ្ងៃសុក្រ ១៣រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៥ ខែមេសា គ.ស.២០២៥ និយ័តករគណនេយ្យនិងសវនកម្ម បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី **"កម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា"**។ សិក្ខាសាលានេះត្រូវបានរៀបចំសម្រាប់សាកលវិទ្យាល័យវិទ្យាស្ថាន គ្រឹះស្ថានអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ សិស្ស-និស្សិត និងសាធារណជន នៅសណ្ឋាគារភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ងី តាយី** រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា។ សិក្ខាសាលានេះរៀបចំឡើងដើម្បីផ្សព្វផ្សាយកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា ជូនដល់សាកលវិទ្យាល័យវិទ្យាស្ថាន គ្រឹះស្ថានអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ សិស្ស-និស្សិត និងសាធារណជន គឺក្នុងគោលបំណងដើម្បីបំពេញតម្រូវការបន្ថែមលើអ្នកជំនាញគណនេយ្យប្រកបដោយគុណវុឌ្ឍិ ស្របតាមកំណើនសេដ្ឋកិច្ចកម្ពុជាដែលកំពុងរីកចម្រើន។

## វគ្គបណ្ដុះបណ្ដាលស្ដីពី "ស្តង់ដារបាយការណ៍ទាក់ទង នឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម"



១៦.កាលពីថ្ងៃសៅរ៍ ១៤រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៦ ខែមេសា គ.ស.២០២៥ និយ័តករគណនេយ្យនិងសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម" សម្រាប់សាធារណជន ក្រោមអធិបតីភាព លោកស្រី នាន បូនី អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម។ វគ្គបណ្តុះបណ្តាលនេះក៏មានការអញ្ជើញចូលរួមពី កញ្ញា វីរៈ បូរមី តំណាងក្រុមហ៊ុនឌីអេស្វស៊ី ព្រមទាំងថ្នាក់ដឹកនាំនិងមន្ត្រីនៃនិយ័តករគណនេយ្យនិងសវនកម្ម ព្រមទាំងសិក្ខាកាមចំនួន៥៧នាក់ផងដែរ។

## កិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពីការគ្រប់គ្រងគុណភាពសវនកម្ម និងការអះអាង



១៧.កាលពីថ្ងៃអង្គារ ៣កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៩ ខែមេសា គ.ស.២០២៥ និយ័តករគណនេយ្យនិងសវនកម្ម បានរៀបចំកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពីការគ្រប់គ្រងគុណភាពសវនកម្មនិងការអះអាង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម និងមានការអញ្ជើញចូលរួមពី ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញ នៃ ន.គ.ស.។

## កិច្ចប្រជុំស្តីពីវឌ្ឍនភាពនៃការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៤ តាមអនឡាញ ( E-Filing )




© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម

១៨.កាលពីថ្ងៃអង្គារ ៤កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៣០ ខែមេសា គ.ស.២០២៥ នៅបន្ទប់ប្រជុំ និយ័តករគណនេយ្យនិងសវនកម្ម បានរៀបចំកិច្ចប្រជុំស្តីពី៖១.វឌ្ឍនភាពនៃការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៤ តាមអនឡាញ សម្រាប់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាប់ចំណេញ,២.ពិភាក្សាទៅលើយន្តការពង្រឹងអនុលោមភាព។ កិច្ចប្រជុំនេះរៀបចំឡើងក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ូ ចារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម និងមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីជំនាញ នៃ ន.គ.ស.។

## កិច្ចប្រជុំពិគ្រោះយោបល់ជាមួយទីប្រឹក្សាបច្ចេកទេសក្រោមក្របខណ្ឌនៃការអនុវត្តគម្រោងការរៀបចំរបាយការណ៍ស្ថិរភាពហិរញ្ញវត្ថុ



១៩.កាលពីថ្ងៃពុធ ៤កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៣០ ខែមេសា គ.ស.២០២៥ នៅទីស្តីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ម៉ូ ចារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម លោកស្រី អេង វណ្ណធដា និងលោក លឹម ចាន់រតនៈ សមាជិកក្រុមការងារស្ថិរភាពហិរញ្ញវត្ថុនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារប្រចាំ ន.គ.ស. បានអញ្ជើញចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ជាមួយទីប្រឹក្សាបច្ចេកទេសក្រោមក្របខណ្ឌនៃការអនុវត្តគម្រោងការរៀបចំរបាយការណ៍ស្ថិរភាពហិរញ្ញវត្ថុ នៃវិស័យហិរញ្ញវត្ថុមិនមែនធនាគារដំណាក់កាលទី២ ក្រោមជំនួយបច្ចេកទេសពី AMRO។ កិច្ចប្រជុំទ្វេភាគីនេះ ប្រព្រឹត្តទៅក្នុងគោលបំណងបង្ហាញនូវលទ្ធផលនៃវឌ្ឍនភាពការងារសម្រេចបានក្រោយបំពេញទស្សនកិច្ចនៅប្រទេសកម្ពុជាលើកទី១, ការតាមដានទិន្នន័យ និងការប្រមូលធាតុចូលបច្ចេកទេស សម្រាប់កិច្ចដំណើរការនៃការងារនៅជំហានបន្ទាប់។

រៀបចំដោយ ÷ **លោក ឡាយ វិចិត្រ**

សម្របសម្រួលអត្ថបទ ÷ **កញ្ញា សុខ ណារី**

© រក្សាសិទ្ធិដោយ និយ័តករគណនេយ្យនិងសវនកម្ម